ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគអាងស្តុកទឹកទំហំ ១២ហិកតា ក្នុងតំបន់បឹងពោងពាយខាងជើង ស្ថិតនៅ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១ .-**

ត្រូវបានធ្វើអនុប្រយោគអាងស្តុកទឹក ទំហំ ១២ហិកតា (ដប់ពីរហិកតា) ក្នុងតំបន់បឹងពោងពាយខាងជើង ស្ថិតនៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 487923.42 | 1282163.20 | 8 | 487841.72 | 1282827.42 |
| 2 | 487718.27 | 1282318.10 | 9 | 487878.71 | 1282813.64 |
| 3 | 487719.41 | 1282953.41 | 10 | 487934.10 | 1282794.85 |
| 4 | 487754.04 | 1282898.30 | 11 | 487921.96 | 1282770.25 |
| 5 | 487770.05 | 1282878.41 | 12 | 487913.68 | 1282746.03 |
| 6 | 487788.53 | 1282859.98 | 13 | 487910.42 | 1282723.99 |
| 7 | 487808.16 | 1282844.90 | 14 | 487909.56 | 1282705.30 |

**មាត្រា២ .-**

ត្រូវបានប្រគល់សិទ្ធិជូនលោកឧកញ៉ា លី យ៉ុងផាត់ កាន់កាប់ជាកម្មសិទ្ធិនូវផ្ទៃដីទំហំ ១២ហិកតាខាងលើ ជាថ្នូរនឹងការសាងសង់ប្រព័ន្ធផ្លូវ និងប្រព័ន្ធប្រឡាយក្នុងតំបន់អភិវឌ្ឍន៍បឹងពោងពាយ និងផ្ទៃដីទំហំ ៨ហិកតា ស្ថិតនៅខណ្ឌជ្រោយចង្វារ សម្រាប់សាងសង់វិមានឈ្នះ-ឈ្នះ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ផែនទីប្រព័ន្ធផ្លូវ និងប្រព័ន្ធប្រឡាយក្នុងតំបន់អភិវឌ្ឍន៍បឹងពោងពាយ




ទំហំផ្ទៃនិងកូអរដោនេចំណុចកំណត់ព្រំ

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 487923.42 | 1282163.20 | 8 | 487841.72 | 1282827.42 |
| 2 | 487718.27 | 1282318.10 | 9 | 487878.71 | 1282813.64 |
| 3 | 487719.41 | 1282953.41 | 10 | 487934.10 | 1282794.85 |
| 4 | 487754.04 | 1282898.30 | 11 | 487921.96 | 1282770.25 |
| 5 | 487770.05 | 1282878.41 | 12 | 487913.68 | 1282746.03 |
| 6 | 487788.53 | 1282859.98 | 13 | 487910.42 | 1282723.99 |
| 7 | 487808.16 | 1282844.90 | 14 | 487909.56 | 1282705.30 |

**និមិត្តសញ្ញា**

- ផ្លូវទំហំ៣០ម៉ែត្រ
- ផ្លូវទំហំ១៥ម៉ែត្រ
- ផ្លូវទំហំ២០ម៉ែត្រ

| សាលារាជធានីភ្នំពេញ | មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ | មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ |
|---|---|---|---|
| លេខ:...... បានឃើញ និងឯកភាព ថ្ងៃទី...ខែ...ឆ្នាំ២០១៥ អភិបាល នៃគណៈអភិបាល រាជធានីភ្នំពេញ | បានឃើញ និងឯកភាព ថ្ងៃទី...ខែ...ឆ្នាំ២០១៥ ប្រធាន | បានឃើញ និងឯកភាព ថ្ងៃទី...ខែ...ឆ្នាំ២០១៥ ប្រធាន | បានឃើញ និងឯកភាព ថ្ងៃទី...ខែ...ឆ្នាំ២០១៥ ប្រធាន |
| ប៉ា សុជាតិវង្ស | ម៉ៅ_ប៊ុនធឿន | សាំ ពិសិដ្ឋ | ជា_ស្រ៊ុន |

សិក្សាដោយ: ទីចាត់ការរៀបចំក្រុង

| | ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|
| រៀបចំដោយ: | ជាម សុភក្ត្រ | | 22/06/2015 |
| ពិនិត្យដោយ: | ស៊ុន បូណារី | | 22/06/2015 |